# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ  សាសនា  ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ ១៩/២០០៣ កបធ

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣

**សូមក្រាបបង្គំទូលថ្វាយ**
**ព្រះករុណាសម្តេចព្រះនរោត្តម  សីហនុ**
**ព្រះមហាក្សត្រ  នៃព្រះរាជាណាចក្រកម្ពុជា**

សូមទ្រង់ព្រះមេត្តាជ្រាប ។

**កម្មវត្ថុ :** ការយាងទៅបើករដ្ឋសភានៃនីតិកាលទី ៣

**យោង :** ព្រះរាជសារ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣

ទូលព្រះបង្គំយើងខ្ញុំ ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលព្រះរាជសារ ដូចមានយោងខាងលើ បានរួមប្រជុំក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣ហើយបានសម្រេចជាឯកច្ឆ័ន្ទថា តាមមាត្រា ៨២នៃរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រត្រូវកោះប្រជុំបើកសម័យប្រជុំដំបូងរដ្ឋសភា ៦០ ថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត ។ ព្រះរាជវត្តមាននៃព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងក្នុងការបើកសម័យប្រជុំដំបូងមានសារៈសំខាន់ណាស់ចំពោះប្រជាជាតិទាំងមូល និង ចំពោះស្ថាប័នដ៏កំពូលនេះ ។ ជាទម្លាប់កន្លងមកព្រះករុណាតែងតែទ្រង់បានផ្តល់កិត្តិយស ដោយព្រះអង្គទ្រង់បានយាងទៅជាព្រះរាជអធិបតីនៃពិធីបើកសម័យប្រជុំដំបូងរបស់រដ្ឋសភា ។

អាស្រ័យហេតុនេះ ទូលព្រះបង្គំយើងខ្ញុំ សូមព្រះរាជានុញ្ញាតថ្វាយយោបល់ថា ព្រះករុណាត្រូវយាងទៅបើករដ្ឋសភានៃនីតិកាលទី ៣ នេះ ។

សូមក្រាបបង្គំទូលថ្វាយ ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ជាទីបំផុត ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**
**ប្រធាន**

**ប៊ិន  ឈិន**